**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ការិយាល័យទំនាក់ទំនងពាណិជ្ជកម្មកម្ពុជា**
**ប្រចាំនៅទីក្រុងណាននីង**

**លេខ** 00126 **កពណក.ណន**

**សូមគោរពជូន**

**ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**<u>កម្មវត្ថុ</u>: របាយការណ៍ ប្រចាំខែសីហា ឆ្នាំ២០១២**

សេចក្តីជូនបានជំរាបជូនក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទមានកិត្តិយសគោរពជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី** មេត្តាជ្រាបនូវរបាយការណ៍ប្រចាំ **ខែសីហា ឆ្នាំ២០១២** ដ៏ខ្ពង់ខ្ពស់ដូចតទៅ:

I. **ការទំនាក់ទំនងផ្សេងៗ:**

- ជួបសំដែងការគួរសមជាមួយលោកនាយកមន្ទីរការបរទេសក្រុងណាននីង ។
- ជួបក្រុមហ៊ុន Sumida Electric (H.K) Co., Ltd. មានបំណងរកទីផ្សារលក់សំភារៈអគ្គីសនីនៅកម្ពុជា។
- ជួបពិភាក្សាជាមួយក្រុមហ៊ុនផលិតថ្នាំបសុពេទ្យសត្វ មានបំណងពង្រីកអាជីវកម្មទៅវិនិយោគទុនពីវៀតណាមទៅកម្ពុជា។
- ទស្សនកិច្ចសិក្សាស្វែងយល់ការផលិតថ្នាំបសុពេទ្យសត្វរបស់ចិននៅវៀតណាម ដើម្បីអូសទាញវិនិយោគទៅកម្ពុជា។
- ជួប CHUKYO University នៃប្រទេសជប៉ុនមានបំណងស្វែងយល់បែបបទ ច្បាប់បទដ្ឋានក្នុងការវិនិយោគនៅកម្ពុជា ។
- ជួបក្រុមហ៊ុន Ningming Huashan Sandalwood Development Co., Ltd. មានបំណងទិញដើមខ្លឹមច័ន្ទនៅកម្ពុជា។
- ជួបក្រុមហ៊ុន Guangxi Nanning Zhong Lei Stone Co., Ltd. មានបំណងស្វែងរកទីផ្សារដើម្បីលក់ថ្មម៉ាបនិងថ្មលាបតំនួសផ្លូវនៅកម្ពុជា ។
- ជួបក្រុមហ៊ុន Guangxi Bijia Micro-biology Co., Ltd. មានបំណងស្វែងរកទិញដំឡូងនៅកម្ពុជា។
- ជួបក្រុមហ៊ុន Guangxi Hailangwende Co., Ltd. មានបំណងទិញអង្ករនិងដំឡូងនៅកម្ពុជា ។
- ជួបក្រុមហ៊ុន China-ASEAN International Chinese League មានបំណងដឹកនាំក្រុមហ៊ុនចិនទៅបំពេញបេសកកម្មពាណិជ្ជកម្មដើម្បីស្វែងយល់សក្តានុពលក្នុងការធ្វើវិនិយោគនៅកម្ពុជា ។
- ទំនាក់ទំនងជាមួយ China-ASEAN Plaza ដើម្បីជំរុញកិច្ចព្រមព្រៀងសហប្រតិបត្តិការពាណិជ្ជកម្មរវាងក្រសួងនិងភាគីចិន ។
- ជួប Guangxi International Exposition Bureau មានបំណងដឹកនាំក្រុមហ៊ុនចិនទៅតាំង

Address: No 11, Zhujin Road, China-ASEAN Business District,
Nanning City, Guangxi, China
Tel/Fax : +86-771-5389496
Email : clo_cambodia@yahoo.com

ពិពរណ៍ពាណិជ្ជកម្មនូវមុខទំនិញចិននៅកម្ពុជា ។

## II. សភាពការណ៍សេដ្ឋកិច្ចនៅសាធារណរដ្ឋប្រជាមានិតចិន:

ក្នុងរយៈពេល៧ខែដើមឆ្នាំ២០១២នេះការផ្លាស់ប្តូរពាណិជ្ជកម្មរបស់ចិនសំរេចបាន2168.37កោដិដុល្លា កើនបាន7.1%ប្រចាំឆ្នាំ ។ការនាំចេញរបស់ចិនក្នុងរយៈពេល៧ខែដើមឆ្នាំ២០១២នេះសំរេចបាន 1131.24 កោដិដុល្លា ឯការនាំចូល សំរេចបាន1037.14 កោដិដុល្លា ។

ដោយឡែកតែក្នុងខែសីហា ឆ្នាំ២០១២នេះ ការផ្លាស់ប្តូរពាណិជ្ជកម្មចិនសំរេចបាន328.73កោដិដុល្លា កើនបាន 2.7% ។ ការនាំ ចេញសំរេចបាន176.94 កោដិដុល្លា ឯការនាំចូលសំរេចបាន151.79កោដិដុល្លា កើនបាន1-4.7% ។

ចំណែកឯការវិនិយោគទុនបរទេស នៅក្នុងប្រទេសចិន ក្នុងរយៈពេល៧ខែដើម ឆ្នាំ២០១២ កើនបាន 92.26% ។

**បណ្តាប្រទេសដែលបានវិនិយោគទៅចិនក្នុងរយៈពេល៧ខែដើមឆ្នាំ២០១២នេះមាន:**

-ហុងកុង (41.9កោដិដុល្លា)

-ជប៉ុន (4.72កោដិដុល្លា)

-សាំងហ្គាពួរ (4.42កោដិដុល្លា)

-តៃវ៉ាន់ (4.04កោដិដុល្លា)

-ស.រ.អា (1.96កោដិដុល្លា).

-សាធារណរដ្ឋកូរ៉េ (1.39កោដិដុល្លា)

-អាល្លឺម៉ង់ (958លានដុល្លា)

-ស្វីស (771លានដុល្លា)

-ហុលឡង់ (698លានដុល្លា)

-អង់គ្លេស (628លានដុល្លា)

សេចក្តីដូចបានជំរាបជូនខាងលើ សូម **ឯកឧត្តម ទេសរដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ ប្រចាំ**ខែសីហា ឆ្នាំ២០១២** ដ៏ខ្ពង់ខ្ពស់ដោយអនុគ្រោះ ។

សូម **ឯកឧត្តម ទេសរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំបាទ ។

ក្រុងណានីង, ថ្ងៃទី 03 ខែកញ្ញា ឆ្នាំ២០១២

**ទីប្រឹក្សាពាណិជ្ជកម្ម**

**អ៊ុច គីមយ៉ុន**

<u>ចម្លងជូន</u>

-អគ្គកុងស៊ុលនៅណានីង

-ឯកសារកាលប្បវត្តិ